**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2012, 16:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល : សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងបណ្ដឹងសាទុក្ខផ្លាមៗរបស់ នួន ជា ពាក់ព័ន្ធនឹង “ការអនុវត្តវិធានដោយសង្ខេបអនុលោមតាមវិធាន ៣៥”**

---

| **<u>ដាក់ដោយ៖</u>** | **<u>ផ្ញើជូន៖</u>** | **<u>ចម្លងជូន៖</u>** |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម គង់ ស្រីម ជាប្រធាន | នួន ជា |
| Andrew CAYLEY | ចៅក្រម Motoo Noguchi | អៀង សារី |
| | ចៅក្រម សោម សិរីវឌ្ឍ | ខៀវ សំផន |
| | ចៅក្រម A. KLONOWIECKAMILART | **មេធាវីការពារក្តី៖** |

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម C. N. JAYASINGHE

ចៅក្រម យ៉ា ណារិន

ចៅក្រមបម្រុង ស៊ិន រិទ្ធ

ចៅក្រមបម្រុង Florence MUMBA

**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

*00២/១៩-0៩-២00៧-អ.វ.ត.ក/អ.ជ.ត.ក*

## I. សេចក្ដីផ្ដើម និងប្រវត្តិនីតិវិធី

១. កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ មេធាវីការពារជនជាប់ចោទ នួន ជា ("មេធាវីការពារក្ដី") បានដាក់ *បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥* ("បណ្ដឹងសាទុក្ខ")[1]។ បណ្ដឹងនេះបានដាក់បន្ទាប់ពីមានសេចក្ដីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើពាក់ព័ន្ធចំនួន ២ ប៉ុន្តែដាច់ដោយឡែកពីគ្នាដែលស្នើសុំឱ្យមានវិធានការជាបន្ទាន់ប្រឆាំងនឹងសម្ដេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ("នាយករដ្ឋមន្ត្រី") អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[2] ("សេចក្ដីសម្រេចដែលរងការជំទាស់")[3]។

២. "សំណើលើកទីមួយ" ដែលត្រូវបានដាក់កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់លោកនាយករដ្ឋមន្ត្រី ដែលបានចាត់ទុក នួន ជា ("ជនជាប់ចោទ") ជា "ឃាតករ និងជនដៃដល់នៃអំពើប្រល័យពូជសាសន៍" បានរំលោភគោលការណ៍នៃការសន្មតជាមុនថាគ្មានទោស និងមានតម្លៃស្មើនឹងការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ[4]។ មេធាវីការពារក្ដីបានស្នើសុំឱ្យអង្គជំនុំជម្រះដាក់ទណ្ឌកម្មលោកនាយករដ្ឋមន្ត្រីចំពោះ "សេចក្ដីថ្លែងការណ៍ដែលធ្វើឱ្យខូចខាត"[5] តាមរយៈ"ការថ្កោលទោសជាសាធារណៈ"[6] (ឬ

---

[1] ឯកសារ **E176/2/1/1** បណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចលើសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុនសែន អនុលោមតាមវិធាន ៣៥, ថ្ងៃទី ១១ ខែ មិថុនា ២០១២។

[2] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨), ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

[3] ឯកសារ **E176/2** សេចក្ដីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១២។

[4] ឯកសារ **E176** សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២។

[5] ឯកសារ **E176** *ដូចឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ២៣។

[6] ឯកសារ **E176** *ដូចឯកសារយោងខាងលើ*។

"ការរិះគន់"[7] ឬ "ការស្តីបន្ទោស"[8]) និង "ការព្រមានជាសាធារណៈ"[9] ដោយអនុលោមតាមវិធាន ៣៥។

៣. "សំណើលើកទី ២" ដែលត្រូវបានដាក់ដោយផ្ទាល់មាត់កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ថ្កោលទោស" លោកនាយករដ្ឋមន្ត្រីចំពោះ "ការបង្កើនសម្ពាធ" របស់គាត់ពាក់ព័ន្ធនឹងសំណើលើកទីមួយ ដោយសំអាងទៅលើសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រីដែលបានគំរាមអំពីចំណាត់ការតាមផ្លូវច្បាប់មកលើ "សមាជិកក្បាលរឹងនៃក្រុមមេធាវីការពារជនជាប់ចោទ នួន ជា"[10]។

៤. នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាសំណើលើកទីមួយ ពុំមានលក្ខណៈអាចឱ្យទទួលយកបានឡើយដោយហេតុថាសំណើនេះជា "សំណើច្រំដែល ឬបណ្តឹងសាទុក្ខក្លែងភេទ"[11]។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកទាំងស្រុងនូវសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា សំណើលើកទីមួយមានក្រោយពេលមានសំណើផ្ទាល់មាត់ដូចគ្នាមួយទៅអង្គជំនុំជម្រះនៅថ្ងៃសវនាការទី១២("សំណើសុំផ្ទាល់មាត់លើកទី១")[12] ដែលខ្លឹមសារនៃសំណើនេះ ត្រូវបានមេធាវីការពារក្តីលើកឡើងចំនួនលើសពីពីរដង ក្នុងអំឡុងរយៈពេល១សប្តាហ៍នៅថ្ងៃសវនាការទី១៨ និង១៩ ហើយបន្ទាប់មក សំណើនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ការ កាលពីអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅថ្ងៃសវនាការទី២៦ ("សេចក្តីសម្រេចដោយផ្ទាល់មាត់")៖

---

7 ឯកសារ **E176** *ដូចឯកសារយោងខាងលើ*។

8 ឯកសារ **E176** *ដូចឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ២៤។

9 ឯកសារលេខ **E176** *ដូចឯកសារយោងខាងលើ*។

10 ឯកសារលេខ **E1/46.1**, ប្រតិចារឹក, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ត្រង់ទំព័រ ៨០, បន្ទាត់ ២០-ទំព័រ ៨១, បន្ទាត់១១។

11 ឯកសារលេខ **E176** *ដូចឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ២៣,៣២។

12 ឯកសារលេខ **E1/24.1** ប្រតិចារឹក, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ត្រង់ទំព័រ ១, បន្ទាត់ ២៣-២៥; ទំព័រ ២, បន្ទាត់ ១-១៥; ទំព័រ៣, បន្ទាត់ ១-១៦។

*នេះជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការជំទាស់របស់មេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងការធ្វើអត្ថាធិប្បាយជា សាធារណៈស្ដីអំពីអត្ថិភាពនៃពិរុទ្ធភាពរបស់កូនក្ដីរបស់គាត់។*

*[15.54.06]*

*អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ការជំទាស់របស់មេធាវីការពារក្ដីដែលថាសេចក្ដីអត្ថាធិប្បាយជាសាធារណៈដែលបានធ្វើតាមប្រព័ន្ធផ្សព្វផ្សាយដែលបានគូសបញ្ជាក់ថាកូនក្ដីរបស់ខ្លួន នួន ជា មានទោសចំពោះបទល្មើសដែលជនជាប់ចោទ បាននឹងកំពុងជំនុំជម្រះនាពេលបច្ចុប្បន្ន។*

*អង្គជំនុំជម្រះសូមបញ្ជាក់ថាមាត្រា៣៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ ហេតុដូច្នេះ ការសម្រេចថាជនជាប់ចោទមានទោស ឬគ្មានទោស គឺជាទំនួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនឹងពិនិត្យពិចារណាលើរាល់អង្គហេតុពាក់ព័ន្ធ ភ័ស្តុតាង សេចក្ដីសន្និដ្ឋាន និងច្បាប់ជាធរមានទាំងអស់នៅ អ.វ.ត.ក។*

*ហេតុដូច្នេះ តុលាការនឹងមិនពិចារណាលើសេចក្ដីអត្ថាធិប្បាយជាសាធារណៈណាមួយ ពាក់ព័ន្ធនឹងពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទណាម្នាក់ក្នុងការចេញសាលក្រមរបស់ខ្លួនឡើយ[13]។*

៥. នៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើលើកទី២លើអង្គសេចក្ដី ដោយបានសម្រេចថាមេធាវីការពារក្ដីខកខានពុំបានបង្ហាញភ័ស្តុតាង ដើម្បីគាំទ្រដល់ការចោទប្រកាន់របស់ខ្លួន ហើយ "តាមលក្ខណៈនៃសេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋ

13 ឯកសារ **E1/38.1** ប្រតិចារឹក, ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ១១៣, បន្ទាត់ ៥-២២។

មន្ត្រី” ពុំញ៉ាំងឲ្យគេជឿដោយសមហេតុផលថាអាចមានការជ្រៀតចូលកិច្ចការរដ្ឋបាលរបស់តុលាការ ឬការរំលោភលើគោលការណ៍នៃការសន្មតជាមុនថាគ្មានទោសឡើយ”[14]។

៦. តាមរយៈនេះ សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសំខាន់ៗចំនួន ២ ចំណុចៈ(i) បណ្តឹងសាទុក្ខចំពោះការចាត់ការសំណើលើកទីមួយ គឺពុំមានលក្ខណៈអាចឲ្យទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះឡើយ ដោយសារភាពយឺតយ៉ាវ [សូមពិនិត្យមើល ផ្នែកII(ក)ខាងក្រោម]; និង (ii) បណ្តឹងសាទុក្ខខកខានពុំបានបំពេញបទដ្ឋាននៃការពិនិត្យមើលឡើងវិញជាធរមាន ដោយសារមូលហេតុនៃ *កំហុសអង្គច្បាប់* [សូមពិនិត្យមើលផ្នែក II(ខ)(ii), ខាងក្រោម] ឬ *ការបំពានជាក់ស្តែងលើឆន្ទានុសិទ្ធិ* [សូមពិនិត្យមើលផ្នែក II(ខ)(iii), ខាងក្រោម]។ សហព្រះរាជអាជ្ញាអះអាងទៀតថា សវនាការផ្ទាល់មាត់ជាសាធារណៈដែលមេធាវីការពារក្តីបានស្នើសុំ[15]គឺពុំចាំបាច់ឡើយនៅដំណាក់កាលនេះ ហើយសហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះសម្រេចលើបណ្តឹងសាទុក្ខនេះជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។

## II. ឧទ្ធិករណ៍

## ក. ការសម្រេចលើសំណើលើកទីមួយមិនមានលក្ខណៈអាចឲ្យទទួលយកបានឡើយ នៅក្នុងបណ្តឹងសាទុក្ខភ្លាមៗ

៧- សហព្រះរាជអាជ្ញាអះអាងថាបណ្តឹងសាទុក្ខនេះ មួយផ្នែកមិនមានលក្ខណៈអាចឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះបានឡើយ ដោយហេតុថាមេធាវីការពារក្តីខកខានពុំបានប្តឹងសាទុក្ខចំពោះចំណាត់ការជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើលើកទីមួយ ឲ្យបានទាន់ពេលវេលា

---

14 ឯកសារ **E176/2** សេចក្តីសម្រេចដែលរងការជំទាស់, ដូចជើងទំព័រលេខ ៣ ត្រង់កថាខណ្ឌ ៣២។

15 ឯកសារលេខ **E176/2/1/1** បណ្តឹងសាទុក្ខ, ដូចជើងទំព័រលេខ ១ ត្រង់កថាខណ្ឌ ២១។

កំណត់ ហើយពុំមានការផ្ដល់ការអនុញ្ញាតណាមួយចំពោះការយឺតយ៉ាវហួសពេលវេលាកំណត់នេះឡើយ។ វិធាន១០៧(១) បានដាក់ពេលវេលាកំណត់ចំនួន៣០ថ្ងៃចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេចសម្រាប់បណ្ដឹងសាទុក្ខភ្លាមៗដោយផ្អែកលើសេចក្ដីសម្រេចដោយអនុលោមតាមវិធាន ៣៥។ សេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២ ខែ កុម្ភៈ ឆ្នាំ២០១២ គឺជាចំណាត់ការដាក់លាក់របស់ខ្លួនលើសំណើសុំផ្ទាល់មាត់លើកទីមួយ ដែលសំណើនោះបង្កើតបានជាខ្លឹមសារនៃសំណើសុំលើកទីមួយ។ ប្រភេទនៃសេចក្ដីសម្រេចផ្ទាល់មាត់ជាចំណាត់ការដាក់លាក់លើបញ្ហានោះដែលបានលើកឡើង បញ្ជាក់ច្បាស់ត្រង់ចំណុចខុសគ្នាចំនួន ៣ នៅក្នុងកំណត់ហេតុលើអង្គហេតុ៖

**ទីមួយ** នៅថ្ងៃសវនាការទី២៦ សេចក្ដីថ្លែងការណ៍ដ៏ច្បាស់លាស់របស់ប្រធានអង្គជំនុំជម្រះទៅភាគីទាំងអស់ ដែលបានលើកអំពីសេចក្ដីសម្រេចលើកទីមួយ៖ "នេះជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការជំទាស់របស់មេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងសេចក្ដីអត្ថាធិប្បាយជាសាធារណៈ ស្ដីពីអត្ថិភាពនៃពិរុទ្ធភាពរបស់កូនក្ដីរបស់ខ្លួន"[16]

**ទីពីរ** នៅថ្ងៃសវនាការថ្ងៃទី២៨ ការរំឭករបស់ប្រធានទៅមេធាវីការពារក្ដីថាអង្គជំនុំជម្រះបាន "ចាត់ការរួចរាល់ហើយ" លើសំណើរបស់មេធាវីការពារក្ដី តបទៅនឹងការព្យាយាមរបស់មេធាវីការពារក្ដី ក្នុងការលើកឡើងជាដដែលៗ អំពីសេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី[17]

**ទីបី** នៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាដំបូង "យល់ឃើញថាសំណើលើកទីមួយនេះ <u>គ្រាន់តែបានពង្រីកវិសាលភាព</u> នៃសំណើមុនៗរបស់មេធាវីការពារក្ដីប៉ុណ្ណោះដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ កាលពីថ្ងៃទី២ ខែកុម្ភៈ

16 ឯកសារ **E1/38.1** ប្រតិចារឹក, ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ១១៣, បន្ទាត់ ៥-៧ [មានការសង្កត់ន័យបន្ថែម]។

17 ឯកសារលេខ **E1/40.1** ប្រតិចារឹក, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤, បន្ទាត់ ១៩។

ឆ្នាំ២០១២"[18]។

៨- ហេតុដូច្នេះ "កាលបរិច្ឆេទនៃសេចក្ដីសម្រេច" លើសំណើលើកទីមួយក្នុងក្របខ័ណ្ឌនៃវិធាន ១០៧(១) គឺថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ហើយបណ្ដឹងសាទុក្ខនានានឹងផុតកំណត់ត្រឹមថ្ងៃទី២ ខែមីនា ឆ្នាំ២០១២។ តាមរយៈប្រធានអង្គជំនុំជម្រះ សហមេធាវីរបស់ជនជាប់ចោទក៏បានដឹងអំពីជម្រើសនៃបណ្ដឹងសាទុក្ខ ក្នុងសេចក្ដីថ្លែងការណ៍ផ្ទាល់មាត់របស់គាត់កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០១២៖

> *អង្គជំនុំជម្រះបានចាត់ការសំណើនេះរួចហើយ។ ហើយនៅពេលដែលអង្គជំនុំជម្រះបានសម្រេចលើសំណើនេះ ហើយលោកមិនពេញចិត្តនឹងការសម្រេចបែបនេះ លោកអាចដាក់បណ្ដឹងសាទុក្ខជំទាស់នឹងសេចក្ដីសម្រេចនេះនៅចំពោះមុខច្បាប់ ហើយលោកមិនមានសិទ្ធិធ្វើសេចក្ដីថ្លែងការណ៍ណាមួយលើបញ្ហា ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនេះបានឡើយ*[19]*។*

៩- ក្នុងកាលៈទេសៈទាំងនេះ សហមេធាវីរបស់ជនជាប់ចោទហាក់ដូចជាបានយល់ឃើញថា នឹងពុំមានឡើយបណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងការសម្រេចលើសំណើសុំផ្ទាល់មាត់លើកទីមួយនេះ ដូចដែលមេធាវីការពារក្ដីបានចង្អុលបង្ហាញនៅក្នុងកិច្ចអន្តរាគមន៍របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសវនាការដដែលនេះ៖

> *លោក PESTMAN៖*
>
> *សូមអរគុណ លោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួន ហើយយើងពិតបានប្ដឹងសាទុក្ខលើសេចក្ដីសម្រេចនេះ ឬសេចក្ដីសម្រេចនានា ដែលយើងគិតថាគួរតែត្រូវបានប្ដឹងសាទុក្ខនៅចុង*

---

18 ឯកសារលេខ **E176/2** សេចក្ដីសម្រេចដែលរងការជំទាស់, ដូចជើងទំព័រលេខ ៣ ត្រង់កថាខណ្ឌ ២៣ [មានគូសបញ្ជាក់បន្ថែម]។

19 ឯកសារលេខ **E1/40.1** ប្រតិចារឹក, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤, បន្ទាត់ ១៩-២៤។

> *បញ្ចប់នៃសំណុំរឿងនេះ។ យើងពុំអាចធ្វើដូច្នោះមុនពេលមានសាលក្រមបានឡើយ។ ប្រាកដណាស់ [យើង]ពុំមែន [ប្តឹងសាទុក្ខជំទាស់នឹង] សេចក្តីសម្រេចនេះឡើយ*[20] ។

១០- ហេតុដូច្នេះ ការបកស្រាយដ៏សមហេតុផលបំផុតនៃកំណត់ហេតុសវនាការគឺថាអង្គជំនុំជម្រះបានស្តាប់សំណើលើកដំបូងរបស់មេធាវីការពារក្តីនេះ បានពិភាក្សាសម្រេចចំនួនប្រមាណ ៣ សប្តាហ៍ និងបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ដោយបានចាត់ការភ្លាមៗលើសំណើនេះ ដែលក្នុងពេលនោះអង្គជំនុំជម្រះក៏បានបញ្ជាក់ជាថ្មីថាខ្លួន "នឹងមិនពិចារណាអំពីយោបល់ជាសាធារណៈណាមួយពាក់ព័ន្ធនឹងពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទណាម្នាក់នៅក្នុងសាលក្រមរបស់ខ្លួនឡើយ"[21]។ ក្នុងការធ្វើដូច្នេះ ខ្លួនបានបដិសេធពុំព្រមអនុវត្តឆន្ទានុសិទ្ធិតាមផ្លូវតុលាការរបស់ខ្លួន ដើម្បីផ្តួចផ្តើមកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៣៥ ដែលជាសេចក្តីសម្រេចមួយដែលជាមូលដ្ឋាននៃបណ្តឹងសាទុក្ខភ្លាមៗទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ដោយអនុលោមតាមវិធាន ១០៤(៤)(ឃ) បានឡើយ។

១១- ការយល់ច្រឡំជាក់ស្តែងអំពីអង្គច្បាប់របស់សហមេធាវីការពារក្តី ចំពោះលទ្ធភាពនៃបណ្តឹងសាទុក្ខភ្លាមៗ ពុំអាចល្មើសនឹងពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខបានឡើយ។ នីតិវិធីប្រកបដោយតម្លាភាពពាក់ព័ន្ធនឹងពេលវេលាកំណត់ ការពន្យារពេល និងការដាក់បណ្តឹងយឺតយ៉ាវ មានអត្ថិភាព ដើម្បីការពារយុត្តិធម៌សម្រាប់ភាគីទាំងអស់ និងដើម្បីធានាបានថាកិច្ចដំណើរការនីតិវិធីនឹងបញ្ចប់ក្នុងពេលសមស្រប ក្នុងលក្ខណៈជាការបញ្ជាក់អំពីគោលការណ៍ជាសារវន្តដូចមានចែងក្នុងវិធាន២១។ ក្នុងកាលៈទេសៈនេះ សហមេធាវីគួរបានស្នើសុំការពន្យារពេល[22] និងឬការជូនដំណឹងអំពី

---

20 ឯកសារលេខ **E1/40.1** *ដូចឯកសារយោងខាងលើ* ត្រង់ទំព័រ ៥, បន្ទាត់ ៦-១០។ [មានការសង្កត់ន័យបន្ថែម]។

21 ឯកសារលេខ **E1/38.1** ប្រតិចារឹក, ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រង់ទំព័រ ១១៣, បន្ទាត់ ២-២២។

22 សេចក្តីណែនាំអនុវត្តន៍ អ.វ.ត.ក /2007/1/វិសោធនកម្មលើកទី ៨, មាត្រា ៨.៥។

ការដាក់ឯកសារយឺតយ៉ាវ[23] ទាក់ទិននឹងការដាក់បណ្តឹងសាទុក្ខ។ តាមរយៈកំណត់ហេតុនេះ សហព្រះរាជអាជ្ញាបានសង្កេតឃើញថាពុំមានចំណាត់ការបែបនេះត្រូវបានអនុវត្តឡើយ។ ពិតណាស់ ការកន្លងផុតនៃពេលវេលាចំនួនជាង៤ខែ ចាប់តាំងពីមានសេចក្តីសម្រេចផ្ទាល់មាត់ ប៉ះពាល់ដល់មូលដ្ឋាននៃបណ្តឹងសាទុក្ខភ្លាមៗ ដើម្បីឱ្យមានការដោះស្រាយបានឆាប់រហ័សនូវបញ្ហាបន្ទាន់បង្ខំនានា ដោយពុំអូសបន្លាយពេល។

១២- ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាអះអាងថាអង្គជំនុំជម្រះគប្បីសម្រេចថាបណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចលើសំណើលើកទីមួយនេះ មិនមានលក្ខណៈអាចឱ្យទទួលយកបានឡើយ ដោយសារមានភាពយឺតយ៉ាវ។

១៣- បណ្តឹងសាទុក្ខភ្លាមៗ អាចមានចំពោះតែសេចក្តីសម្រេច ៤ ប្រភេទរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ៖ (i) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី (ii) សេចក្តីសម្រេចស្តីពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយអនុលោមតាមវិធាន ៨២ (iii) សេចក្តីសម្រេចលើវិធានការការពារ ដោយអនុលោមតាមវិធាន ២៩(៤)(គ) និង (iv) សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ អនុលោមតាមវិធាន៣៥(៦)[24]។ សេចក្តីសម្រេចផ្សេងទៀតរបស់អង្គជំនុំជម្រះសាលាដំបូង "អាចប្តឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី"[25]។ ជាមួយគ្នានេះដែរ បណ្តឹងសាទុក្ខភ្លាមៗ "មិនមានអានុភាពបង្អង់នីតិវិធីមុខអង្គជំនុំជម្រះសាលាដំបូងទេ"[26]។ សហព្រះរាជអាជ្ញាឯកភាពទាំងស្រុងជាមួយការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាសំណើលើក

---

23 សេចក្តីណែនាំអនុវត្តន៍ អ.វ.ត.ក /2007/1/វិសោធនកម្មលើកទី៨, មាត្រា៩។

24 វិធាន ១០៤(៤)។

25 វិធាន ១០៤(៤)។

26 វិធាន ១០៤(៤)។

ទីពីរគឺជាសំណើដាច់ដោយឡែកមួយ ដោយអនុលោមតាមវិធាន ៣៥[27]។ សហព្រះរាជអាជ្ញាយល់ឃើញថាសេចក្តីសម្រេចលើសំណើលើកទីពីរ គឺជាសេចក្តីសម្រេចមួយដែលអាចប្តឹងសាទុក្ខភ្លាមៗបានតាមវិធាន ១០៤(៤)(ឃ)។

## ខ. បណ្តឹងសាទុក្ខមិនស្របនឹងបទដ្ឋានជាធរមាននៃការពិនិត្យឡើងវិញ

### *i. បទដ្ឋានជាធរមាននៃការពិនិត្យឡើងវិញ*

១៤- វិធាន ១០៤(១) បង្កើតជាយុត្តាធិការពិនិត្យឡើងវិញទៅលើបណ្តឹងសាទុក្ខទូទៅរបស់អង្គជំនុំជម្រះដែលកំហិតត្រឹមតែ៖ (i) កំហុសលើបញ្ហាអង្គច្បាប់ដែលមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (ii) កំហុសលើអង្គហេតុដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬ (iii) សម្រាប់តែបណ្តឹងសាទុក្ខភ្លាមៗប៉ុណ្ណោះ កំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យខូចប្រយោជន៍ដល់ម្ចាស់បណ្តឹងសាទុក្ខ[28]។ បទដ្ឋានទាំងបីតាមផ្លូវច្បាប់នេះត្រូវបានឆ្លុះបញ្ចាំងដោយពុំលម្អៀងនៅក្នុងវិធាន ១០៥(២) ដែលបង្កើតជាលក្ខខណ្ឌតម្រូវសម្រាប់ទទួលយកបណ្តឹងសាទុក្ខ និងដោយអនុវត្តទៅតាមបទដ្ឋានជាធរមាននៃការពិនិត្យឡើងវិញ។ ហេតុនេះ អង្គជំនុំជម្រះអាចទទួលយកបណ្តឹងសាទុក្ខបានតែក្នុងករណីដែលខ្លួនសន្និដ្ឋានដោយផ្អែកលើតុល្យភាពនៃភវនីយភាពថា៖ (i) កំហុសលើបញ្ហាអង្គច្បាប់ដែលមោឃៈសេចក្តីសម្រេចដែលត្រូវបានជំទាស់ (ii) កំហុសលើអង្គហេតុដែលនាំឲ្យមានភាពមិនយុត្តិធម៌ ឬ (iii) សម្រាប់តែបណ្តឹងសាទុក្ខភ្លាមៗប៉ុណ្ណោះ កំហុសជាក់ស្តែងក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យខូចប្រយោជន៍ដល់ម្ចាស់បណ្តឹងសាទុក្ខ។

---

27 ឯកសារ **E176/2** សេចក្តីសម្រេចដែលរងការជំទាស់, ដូចជើងទំព័រលេខ ៣ កថាខណ្ឌ ២៤។

28 វិធាន ១០៤(១)។

១៥- អង្គជំនុំជម្រះនេះបានបញ្ជាក់ច្បាស់ពីវិសាលភាពនៃវិធាន ១០៤(១) ដោយកត់សម្គាល់ថា កំហុសជាក់ស្ដែងរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន “ពុំ ... បង្កើតជាសំអាងហេតុដាច់ខាតសម្រាប់បណ្ដឹងសាទុក្ខទេ”[29]។ អង្គជំនុំជម្រះនេះក៏បានអះអាងសាជាថ្មីនូវអំណាចមានកម្រិតរបស់ខ្លួនក្នុងការពិនិត្យឡើងវិញទៅលើបណ្ដឹងសាទុក្ខ ដោយសារវាខុសពីអំណាចដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះផ្សេងទៀត[30]។ ជាងនេះទៀត នៅពេលសម្រេចពីវិសាលភាពនៃការពិនិត្យឡើងវិញទៅលើបណ្ដឹងសាទុក្ខដែលសមស្របនោះ “ជាតុលាការចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលត្រូវពិនិត្យឡើងវិញ អំពីសេចក្ដីសម្រេចដែលតវ៉ាតែទៅលើទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ និងស្របតាមគោលបំណងនៃបណ្ដឹងសាទុក្ខប៉ុណ្ណោះ”[31]។ នោះគឺថា វិសាលភាពនៃការពិនិត្យឡើងវិញទៅលើបណ្ដឹងសាទុក្ខគឺត្រូវបានកំណត់ដោយបណ្ដឹងសាទុក្ខនោះឯង។ ចំណុចនេះមិនបានរារាំងអង្គជំនុំជម្រះមិនឲ្យបង្ហាញសំអាងហេតុរបស់ខ្លួននោះទេ តែបញ្ហាក្នុងបណ្ដឹងសាទុក្ខដែលកំពុងត្រូវបានពិចារណាដោយអង្គជំនុំជម្រះត្រូវតែជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខ ហើយត្រូវតែជាសំអាងហេតុដែលអនុញ្ញាតឲ្យកែតម្រូវតាមការស្នើសុំរបស់ម្ចាស់បណ្ដឹងសាទុក្ខ[32]។

១៦- តុលាការ *មិនអចិន្ត្រៃយ៍*នានាបានអនុម័តយកវិធីសាស្ត្រតឹងតែងស្រដៀងគ្នានេះដែរ នៅពេលដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការពិនិត្យឡើងវិញទៅលើបណ្ដឹងសាទុក្ខ ដែលគាំទ្រទស្សនៈដែលថា មុខងារបឋមរបស់យុត្តាធិការពិនិត្យឡើងវិញទៅលើបណ្ដឹងសាទុក្ខគឺការកែតម្រូវ។ លក្ខន្តិកៈតុលាការ ICTY និង

---

29 ឯកសារ **E50/3/1/4**, សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១។

30 *ដូចយោងខាងលើ* ត្រង់កថាខណ្ឌ ៥៣។

31 *ដូចយោងខាងលើ* ត្រង់កថាខណ្ឌ ៥២។

32 *ដូចយោងខាងលើ*។

ICTR បានថែងយ៉ាងចង្អៀតនូវបទដ្ឋាននៃការពិនិត្យឡើងវិញទៅលើបណ្តឹងសាទុក្ខ ដែលត្រូវបានយុត្តិសាស្ត្រអង្គជំនុំជម្រះសាលាឧទ្ធរណ៍សង្កត់ធ្ងន់គឺថា៖ “... ខណៈដែលអង្គជំនុំជម្រះ *អាច*យល់ថា ជាការចាំបាច់ក្នុងការដោះស្រាយបញ្ហានានានោះ [ពួកគេ] *ក៏អាច* យល់ថាមិនចាំបាច់ដែរ”[33]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍ “នឹងមិនពិចារណាទៅលើបញ្ហាទាំងអស់ដែលច្រើនសន្នឹកសន្នាប់នោះទេ។ ការពិត បញ្ហានានាដែលបានលើកឡើង ត្រូវតែជាផលប្រយោជន៍នៃការអនុវត្តច្បាប់របស់តុលាការ និងត្រូវតែមានចំណងទាក់ទងជាមួយរឿងក្តីដែលដំណោះស្រាយ”[34]។

១៧- នៅក្នុងការអនុវត្តរបស់តុលាការ *មិនអចិន្ត្រៃយ៍* បទដ្ឋានជាក់លាក់នៃការពិនិត្យឡើងវិញទៅលើបណ្តឹងសាទុក្ខសម្រាប់កំហុសលើអង្គច្បាប់ផ្ទុះបញ្ចាំងនៅក្នុងវិធាន ១០៥ ដូចបានលើកឡើងខាងលើ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍មានយុត្តាធិការផ្តាច់មុខលើ “កំហុសលើអង្គច្បាប់ដែលមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង”[35]។ ក្នុងការអនុវត្តចាំបាច់ កំហុសលើអង្គច្បាប់ទាំងអស់មិនសុទ្ធតែស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញទៅលើបណ្តឹងសាទុក្ខទេ។ បើតាមលក្ខណៈ និងផលវិបាករបស់វា មានកំហុសលើអង្គច្បាប់មួយចំនួនធំពុំមោឃៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទេ។

---

33 លក្ខន្តិកៈតុលាការ ICTY; លក្ខន្តិកៈតុលាការ ICTR; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jean-Paul Akayesu*, ICTR-96-4-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ២៤ [គូសបញ្ជាក់បន្ថែម]; ត្រូវបានដកស្រង់ដោយមានការឯកភាពនៅក្នុង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, សំណុំរឿងលេខ IT-97-25-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ត្រង់កថាខណ្ឌ ៨។

34 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Jean-Paul Akayesu*, សំណុំរឿងលេខ ICTR-96-4-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ ត្រង់កថាខណ្ឌ ២៤; ត្រូវបានដកស្រង់ដោយមានការឯកភាពនៅក្នុង*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, សំណុំរឿងលេខ IT-97-25-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ត្រង់កថាខណ្ឌ៨។

35 *រឿងក្តី François Karera តទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-01-74-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រង់កថាខណ្ឌ ៧។

១៨- ឧទាហរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានដឹងថា អង្គជំនុំជម្រះសាលាដំបូង "បានប្រព្រឹត្តកំហុសជាក់ស្តែងលើអង្គច្បាប់" តែដោយសារកំហុសនោះមិនបាន "មោឃៈ [...] សាលក្រមសាលាដំបូង" ចំណុចជាក់លាក់នៃបណ្តឹងសាទុក្ខនោះត្រូវបានបដិសេធចោល[36]។ នៅក្នុងករណីនេះ ម្ចាស់បណ្តឹងសាទុក្ខ Siméon Nchamihigo បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារចាប់ផ្តើមការជំនុំជម្រះក្តីរូបគាត់មុនពេលដោះស្រាយបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងវិការៈនៃទម្រង់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាបញ្ហាមួយដែលសំខាន់ដល់សិទ្ធិក្នុងការការពារខ្លួន ដោយសារកិច្ចដំណើរការនីតិវិធីនៅតុលាការ *មិនអចិន្ត្រៃយ៍*មានលក្ខណៈតទល់ដោយគូភាគី។ ក្នុងការឆ្លើយតបវិញ ខាងអយ្យការបានអះអាងថា ម្ចាស់បណ្តឹងសាទុក្ខខកខានមិនបានបង្ហាញពីការប៉ះពាល់ដល់លទ្ធភាពរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការរៀបចំការការពារខ្លួនឲ្យមានប្រសិទ្ធភាព។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានរំលោភលើបញ្ញត្តិជាក់ស្តែងនៃវិធាន ៧២(ក) ពាក់ព័ន្ធនឹងការចេញសេចក្តីសម្រេចលើសំណើបឋមនានា មុនពេលចាប់ផ្តើមសវនាការ តែអង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនទទួលស្គាល់ថា កំហុសនេះមោឃៈសាលក្រមសាលាដំបូងទេ ហើយក៏បានបដិសេធទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ[37]។ ហេតុនេះ ដើម្បីឲ្យស្របទៅតាមបទដ្ឋាននៃការពិនិត្យឡើងវិញទៅលើបណ្តឹងសាទុក្ខជាធរមានចំពោះកំហុសលើអង្គច្បាប់ សហព្រះរាជអាជ្ញាលើកឡើងថា ម្ចាស់បណ្តឹងសាទុក្ខមិនត្រឹមតែត្រូវបញ្ជាក់ឲ្យបានច្បាស់ពីកំហុសនោះទេ តែក៏ត្រូវតែបង្ហាញដោយផ្អែកលើតុល្យភាពនៃភវនីយភាពថា តើកំហុសនេះមោឃៈដីកាដែលត្រូវបានជំទាស់ដោយរបៀបណា។

---

36 *រឿងក្តី Siméon Nchamihigo តទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ ICTR-2001-63-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR) ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ត្រង់កថាខណ្ឌ ៣១-៣២។

37 *ដូចយោងខាងលើ*។

១៩- អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានវាយតម្លៃពីកត្តានានានៃការអនុវត្តឆន្ទានុសិទ្ធិដែលនឹងពាក់ព័ន្ធនឹងបទដ្ឋាននៃការពិនិត្យឡើងវិញនៅតុលាការនោះថា៖

> *អាស្រ័យហេតុនេះ ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង [...] ពុំមានសំអាងហេតុត្រឹមត្រូវ និងអយុត្តិធម៌សុទ្ធសាធដែលធ្វើឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ*[38] ។

២០- បទដ្ឋាននៃការពិនិត្យឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍ដោយអង្គបុរេជំនុំជម្រះនៅ អ.វ.ត.ក មានកម្រិតខ្ពស់ជាង ដោយតម្រូវឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញពី “ការបំពាន” អំណាចឆន្ទានុសិទ្ធិដោយសម្អាងលើភាពមិនយុត្តិធម៌ និងមិនសមហេតុសមផល[39]។ សហព្រះរាជអាជ្ញាលើកឡើងថា បទដ្ឋានដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ដែលតម្រូវថាអង្គជំនុំជម្រះ

---

[38] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zdravko Tolimir* និងគូកន, សំណុំរឿងលេខ IT-04-80-AR65.1, សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលយល់ព្រមដោះលែងបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២00៥ ត្រង់កថាខណ្ឌ ៤។

[39] ឯកសារលេខ **D164/4/13** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចលើសំណើសុំភស្តុតាងដោះបន្ទុកក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២00៩ ត្រង់កថាខណ្ឌ ២២-២៧ (ដែលបានដកស្រង់ពីក្នុង *រឿងក្តី Slobodan Milošević v. តទល់នឹង រដ្ឋអាជ្ញា*, សំណុំរឿងលេខ IT-02-54-AR73.7, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេច់របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការចាត់តាំងមេធាវីការពារក្តី សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY) ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២00៤ ត្រង់កថាខណ្ឌ ៩-១0); ឯកសារលេខ **D140/9/5** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ដែលបដិសេធសំណើរបស់គាត់ សុំតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមមួយរូប ដើម្បីធ្វើការពិនិត្យឡើងវិញទៅលើខ្លឹមសារនៃរបាយការណ៍របស់អ្នកជំនាញដែលបានដាក់ជូនលោកស្រី Ewa Tabeau និងលោក ថឺ ឃាម ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២0១0 ត្រង់កថាខណ្ឌ ១៥-១៧; ឯកសារលេខ **D356/2/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំយោបល់ពីអ្នកជំនាញជាលើកទីពីរ ថ្ងៃទី ១ កក្កដា ឆ្នាំ ២0១0 ត្រង់កថាខណ្ឌ ១៦-១៨។

សាលាដំបូង “ខកខានមិនបានអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវ” ស្រដៀងគ្នានឹង “កំហុសជាក់ស្តែងក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង” ដែលតម្រូវដោយវិធាន ១០៥ និងជាធរមាននៅចំពោះមុខអង្គជំនុំជម្រះនេះ។ បទដ្ឋានដែលអនុវត្តដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុង*រឿងក្តី Tolimir* នឹងទទួលយកបាន លុះត្រាតែសេចក្តីសម្រេចដែលត្រូវបានជំទាស់ “មិនសមហេតុផលខ្លាំង និងមិនយុត្តិធម៌ទាល់តែសោះ” ដែលអនុញ្ញាតឲ្យមានការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តអំណាចឆន្ទាសិទ្ធិឲ្យបានត្រឹមត្រូវ។ ពាក្យពេចន៍អាចត្រូវបានចាត់ទុកថាជាការតម្រូវឲ្យមានទាំង *ភាពមិនសមហេតុផលបែបកម្រោល* និង *ភាពអយុត្តិធម៌សុទ្ធសាធ (ឬជាក់ស្តែង)* មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិដោយអង្គជំនុំជម្រះសាលាដំបូងត្រូវបានច្រានចោលចំពោះបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះគួរអនុវត្តបទដ្ឋានមួយស្រដៀងគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។

ii. *អង្គជំនុំជម្រះមិនបានប្រព្រឹត្តកំហុសផ្នែកច្បាប់ដើម្បីមោឃៈសេចក្តីសម្រេចដែលកំពុងតវ៉ានេះទេ*

២១- បើអង្គជំនុំជម្រះគាំទ្រដល់ការទទួលយកបណ្តឹងសាទុក្ខទាក់ទងនឹងសំណើសុំលើកទីមួយ នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្តីសម្រេចដែលរងការជំទាស់មិនបានបង្ហាញឲ្យឃើញពីកំហុសឆ្គងផ្នែកច្បាប់ណាមួយ ដូចមេធាវីការពារក្តីបានចោទប្រកាន់ឡើយ នៅក្នុង: (i) “ការស្វែងរកដំណោះផ្លូវច្បាប់យ៉ាងប៉ិនប្រសប់” ចំពោះការរំលោភលើសច្ចធារណ៍នៃនិរទោសដូចដែលគេបានពោលអះអាង[40] ឬ (ii) ប្រកា◌ាសថាសំណើសុំលើកទីមួយមិនអាចទទួលយកបាន ដោយសារវាជា “ការដាក់សារឡើងវិញ ឬជាបណ្តឹងសាទុក្ខលាក់បាំង”[41]។

២២- ដូចបានពិភាក្សាក្នុងវក្យខណ្ឌ II(ខ)(i) ខាងលើ ដើម្បីបំពេញតាមបទដ្ឋាននៃការត្រួតពិនិត្យអំពីកំហុស

[40] **E176/2/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់*ខាងដើម*លេខ១ ត្រង់កថាខណ្ឌទី១៣។

[41] **E176/2/1/1** *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី១៩។

ឆ្គងផ្នែកច្បាប់ ដើមបណ្តឹងសាទុក្ខមិនត្រឹមតែត្រូវកំណត់ពីអត្តសញ្ញាណនៃកំហុសដូចបានអះអាងប៉ុណ្ណោះទេ ប៉ុន្តែដោយឈរលើតុល្យភាពនៃភវនីយភាព ត្រូវបង្ហាញភ័ស្តុតាងឲ្យឃើញថា កំហុសឆ្គងនោះ *ធ្វើឲ្យអស់សុពលភាព* ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ លក្ខខណ្ឌតម្រូវទាំងពីរគឺជាលក្ខខណ្ឌត្រូវបូកបញ្ចូលគ្នា។ តាមតួរយ៉ាងនេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់នូវការជំទាស់របស់សហមេធាវីការពារក្តីចំពោះសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី និងបានពិនិត្យថា តើចំណាប់អារម្មណ៍នេះមានតម្លៃស្មើនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលដែរ ឬអត់។ នៅក្រោមវិធាន៣៥(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ត្រូវបានផ្តល់អំណាចឲ្យ "ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាល"[42]។ តាមវិធាន៣៥(២) បើសិនសកម្មភាពមួយបង្ហាញឲ្យឃើញពី "ហេតុផលឲ្យជឿបាន" ថាការជ្រៀតជ្រែកនោះបានកើតឡើងមែន នោះតាមឆន្ទានុសិទ្ធរបស់ខ្លួន អង្គជំនុំជម្រះអាចអនុវត្តតាមមធ្យោបាយមួយក្នុងចំណោមផ្លូវទាំងបីដូចតទៅ: ចាត់ការជាមួយបញ្ហាជាបន្ទាន់ដឹកនាំកិច្ចស៊ើបសួរបន្ថែម ដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬបញ្ជូនបញ្ហានេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជា ឬអង្គការសហប្រជាជាតិ[43]។

២៣- ទីមួយ កង្វល់អំពីកំហុសឆ្គងផ្នែកច្បាប់ដូចបានចោទប្រកាន់ដោយមេធាវីការពារក្តី គឺពាក់ព័ន្ធទៅនឹងជម្រើសនៃដំណោះស្រាយ។ ដោយបានទទួលស្គាល់ថាចំណាប់អារម្មណ៍ដែលជាប់ទាក់ទងទៅនឹងនាយករដ្ឋមន្ត្រីបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន៣៥(២)[44] អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីចាត់ការជាមួយបញ្ហានេះដោយបន្ទាន់ - ដែលជាដំណោះស្រាយមួយ ដែលបានរំពឹងទុកច្បាស់លាស់ដោយមេធាវីការពារក្តី តាមអ្វីដែលបានរចនាឡើងក្នុងសំណើសុំលើកទីមួយថា សំណើសុំ "<u>វិធានការជាបន្ទាន់</u>... នៅក្រោមវិធាន៣៥"។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា

---

[42] វិធាន៣៥(១) នៃវិធានផ្ទៃក្នុង។

[43] វិធាន៣៥(២) នៃវិធានផ្ទៃក្នុង។

[44] **E176/2** សេចក្តីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងដើម*លេខ៣ ត្រង់កថាខណ្ឌទី២៥។

ចំណាប់អារម្មណ៍របស់នាយករដ្ឋមន្ត្រីតាមដែលគេបានចោទប្រកាន់នោះបានរំលោភទៅលើសច្ចធារណ៍នៃនិរទោស តាមរយៈការអះអាងអំពីសិទ្ធិរបស់ចុងចោទទាំងអស់ក្នុងការសន្មតការព្រមានមន្ត្រីផ្សេងៗ មិនឱ្យធ្វើសេចក្ដីអធិប្បាយដែលវិសមិតភាពនឹងការសន្មតនេះ និងដោយការសង្កត់ធ្ងន់ថា សេចក្ដីថ្លែងការណ៍នេះទោះតាមផ្លូវណាក៏ដោយ មិនអាចជ្រៀតជ្រែកទៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តរបស់អង្គជំនុំជម្រះបានឡើយ[45]។ ទាក់ទងនឹងដំណោះស្រាយដែលបានផ្ដល់ឱ្យជនជាប់ចោទនៅក្នុងទម្រង់ជា "ការរំលឹកជាសាធារណៈដែលមានន័យច្បាស់លាស់"[46] ទម្រង់នៃសំណងទូទាត់ប្រកាសសិទ្ធិតែមួយ អនុវត្តតាមករណីយុត្តិសាស្ត្រផ្នែកសិទ្ធិមនុស្សដែលសាលក្រមប្រកាសសិទ្ធិ ត្រូវបានផ្ដល់ឱ្យជាឧបាស្រ័យតែមួយគត់ចំពោះអំពើរំលោភសិទ្ធិមនុស្សដោយអង្គការរដ្ឋ។ ជាពិសេស ទាំងតុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ("ECtHR") និងទាំងតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកកាំង ("IACtHR") បានសម្រេចដដែលៗថា សំណងទូទាត់ប្រកាសសិទ្ធិតែមួយអាចជាឧបាស្រ័យគ្រប់គ្រាន់មួយនៃការបំពេញចិត្តដោយយុត្តិធម៌ សម្រាប់បុគ្គលណាម្នាក់ដែលសិទ្ធិមនុស្សរបស់គាត់ត្រូវបានគេរំលោភ។

២៤- ក្នុងមាត្រា ៤១ នៃអនុសញ្ញាអ៊ឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ("ECHR")៖ *ប្រសិនបើតុលាការរកឃើញថាមានការរំលោភអនុសញ្ញានេះ ឬពិធីសារនៃអនុសញ្ញានេះ ហើយប្រសិនបើច្បាប់ផ្ទៃក្នុងរបស់តំណាងភាគីរដ្ឋសាមុី អនុញ្ញាតឱ្យមានសំណងជួសជុលតែមួយផ្នែក តុលាការត្រូវលៃលកធ្វើយ៉ាងណាឱ្យការបំពេញចិត្ត ត្រូវបានធ្វើឡើង ដោយយុត្តិធម៌ចំពោះភាគីដែលរងគ្រោះ បើសិនជាចាំបាច់"*[47]។

មាត្រានេះខុសពីវិធាន៣៥ ដែលវាមិនមែនអនុវត្តត្រឹមតែឧបាស្រ័យនានានៃការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងគ្រប់ដណ្ដប់ទៅលើវិសាលគមជាសក្ដានុពលនៃការរំលោភសិទ្ធិមនុស្សដែលទទួលបានការការពារដោយអនុសញ្ញា ECHR។ ខណៈដែលវិធាន៣៥ បញ្ជាក់អំពីឧបាស្រ័យបីយ៉ាងដែលសមរម្យសម្រាប់ករណីនៃការជ្រៀតជ្រែកផ្សេងៗ មាត្រា៤១សំដៅលើ

---

[45] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី២៧, ២៩ និង៣១។

[46] **E176/2** សេចក្ដីសម្រេចដែលរងការជំទាស់, កំណត់សម្គាល់*ខាងដើម* លេខ៣ ត្រង់កថាខណ្ឌទី៣១។

[47] អនុសញ្ញាស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ៤ វិច្ឆិកា ១៩៥០, ២១៣ UNTS 221, មាត្រា៤១។

"ការបំពេញចិត្តដោយយុត្តិធម៌" ដោយលៃទុកនូវកម្រិតមួយនៃឆន្ទានុសិទ្ធិឱ្យដល់តុលាការ ECtHR ដែលអាចប្រៀបធៀបបានជាមួយនឹងបទប្បញ្ញត្តិនៃវិធាន៣៥ ដែលថា សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ "ចាត់ការជាមួយបញ្ហាជាបន្ទាន់"។ តាមមាត្រា៤១ តុលាការ ECtHR បានអនុវត្តនូវសំណងទូទាត់ប្រកាសសិទ្ធិ ដើម្បីចាត់ការចំពោះការរំលោភផ្សេងៗដែលគេអាចអះអាងបានថា ធ្ងន់ធ្ងរជាងសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី។

២៥- ជាឧទាហរណ៍ ក្នុងរឿងក្តី *Nikolova ទល់នឹងប្រទេសប៊ុលហ្គារី,* តុលាការ ECtHR បានសន្និដ្ឋានថា ការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះការឃុំឃាំងរបស់អ្នកដាក់សំណើសុំ រួមទាំង នីតិវិធីស្តីពីការឃុំឃាំង ខកខានមិនបានបំពេញទៅតាមបទដ្ឋានដូចមានចែងយ៉ាងពិស្តារ នៅក្នុងមាត្រា៥(៤)នៃអនុញ្ញានេះ[48] ដែលចែងថា "ជនណាដែលសេរីភាពរបស់ខ្លួនត្រូវបានដកហូតតាមរយៈការចាប់ខ្លួន ឬការឃុំឃាំង ត្រូវមានសិទ្ធិទទួលបាននូវកិច្ចដំណើរការនីតិវិធីស្តីពីភាពស្របច្បាប់នៃការឃុំឃាំងរបស់គាត់ ដោយត្រូវសម្រេចឱ្យបានឆាប់រហ័សដោយតុលាការ និងត្រូវបង្គាប់ឱ្យដោះលែងរូបគាត់ បើសិនជាការឃុំខ្លួនគាត់ធ្វើឡើងដោយខុសច្បាប់"[49]។ ទោះបីការសម្រេចរបស់តុលាការមានន័យច្បាស់លាស់ថា ការរំលោភបានកើតឡើងមែនក៏ដោយ ក៏តុលាការមិនបាននឹកស្មានដល់ "ថាតើអ្នកស្នើសុំនឹងត្រូវបានគេឃុំខ្លួនដែរ ឬអត់ បើសិនជាគ្មានការរំលោភអនុសញ្ញានេះ"[50] ផ្ទុយមកវិញតុលាការនេះបានសម្រេចថា "ការរកឃើញអំពីការរំលោភ" បង្កើតបានជាឧបាស្រ័យប្រហាក់ប្រហែលគ្នាមួយ[51]។ ក្នុងរឿងក្តី *Nikolova,* "ការរកឃើញអំពីការរំលោភ"របស់តុលាការ ត្រូវបានចាត់ទុកថាជា "ការបំពេញចិត្តដោយយុត្តិធម៌" ទោះបីជាវាមិនបានបញ្ចូលការប្រមានជាសាធារណៈណាមួយដូចអង្គជំនុំជម្រះសាលាដំបូងបានចេញ នៅក្នុងការដោះស្រាយបញ្ចប់លើសំណើសុំលើកទីមួយក៏ដោយ។

---

48 ករណី *Nikolova ទល់នឹងប្រទេសប៊ុលហ្គារី,* សំណើសុំលេខ ៣១១៩៥/៩៦, សាលក្រម: អង្គសេចក្តី និងការបំពេញចិត្តដោយយុត្តិធម៌ (អង្គជំនុំជម្រះខ្នាតធំរបស់ ECHR), ២៥ មីនា ១៩៩៩, ត្រង់កថាខណ្ឌ៦៥។

49 អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, កំណត់សម្គាល់*ខាងដើម* លេខ៤៧ ត្រង់មាត្រា៥(៤)។

50 ករណី *Nikolova,* កំណត់សម្គាល់*ខាងដើម* លេខ៤៨ ត្រង់កថាខណ្ឌ៧៦។

51 *ដដែលដូចខាងលើ* ។

២៦- ក្នុងរឿងក្តី*Ocalan ទល់នឹងប្រទេសតួរគី,* តុលាការ ECtHR ជាថ្មីម្តងទៀតបានសម្រេចថា ការរកឃើញរបស់ខ្លួនចំពោះការរំលោភមាត្រា៣, ៥ និង ៦ នៃអនុសញ្ញានេះ (ដែលចាត់ការរៀងៗគ្នាអំពីការហាមឃាត់ចំពោះអំពើបន្ទាបបន្ថោក សិទ្ធិក្នុងការទទួលបានសេរីភាព និងសន្តិសុខរបស់បុគ្គល និងសិទ្ធិទទួលបានសវនាការដោយតុលាការឯករាជ្យ) មាន "បង្កប់នៅក្នុងខ្លួនវាផ្ទាល់នូវការបំពេញចិត្តដោយយុត្តិធម៌គ្រប់គ្រាន់សម្រាប់ការខូចខាតណាមួយ ដែលអ្នកដាក់ពាក្យសុំបានទទួលរង"[52]។ នៅក្នុងចំណោមដំណោះស្រាយផ្សេងៗ ECtHR បានបង្កើតភាពសមស្របនៃសំណងទូទាត់ប្រកាសសិទ្ធិដូច្នេះបន្ថែមទៀតក្នុងករណី *Golder ទល់នឹងចក្រភពអង់គ្លេស*[53] និង *Marckx ទល់នឹងប្រទេសបែលស៊ិក*[54] ។

២៧- ដើម្បីរក្សាករណីនេះឲ្យស្របទៅនឹងករណីនានារបស់តុលាការ ECtHR ករណីយុត្តិសាស្ត្ររបស់ IACtHR ក៏ផ្តល់ការគាំទ្រដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែរ ដើម្បីជាការផ្តល់នូវសំណងទូទាត់ប្រកាសសិទ្ធិ ក្នុងការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍ដែលជាប់ទាក់ទងជាមួយនាយករដ្ឋមន្ត្រី។ ឧទាហរណ៍ ក្នុងករណី *Villagrán Morales និងគូកន ទល់នឹង Guatemala*, IACtHR បានថ្លែងថា "តុលាការនេះ ដូចសាលាក្តីអន្តរជាតិដទៃទៀតដែរ បានបញ្ជាក់ម្តងហើយម្តងទៀតថា សាលក្រមផ្តន្ទាទោសណាមួយ ខ្លួនវាផ្ទាល់អាចជាទម្រង់មួយនៃសំណងទូទាត់ចំពោះការខូតខាតមិនមែនជាប្រាក់កាស"[55]។ ការផ្តល់សំណងទូទាត់ខាងហិរញ្ញវត្ថុដល់ភាគីដែលរងរបួស ដោយសារតែ

---

[52] ករណី *Ocalan ទល់នឹងប្រទេសតួរគី,* សំណើសុំលេខ ៤៦២២១/៩៩, សាលក្រម: អង្គសេចក្តី និងការបំពេញចិត្តដោយយុត្តិធម៌ (អង្គជំនុំជម្រះខ្នាតធំរបស់ ECHR), ១២ ឧសភា ២០០៥ នៅ Holdings, កថាខណ្ឌ១៥។

[53] ករណី *Golder ទល់នឹង ចក្រភពអង់គ្លេស,* សំណើសុំលេខ ៤៤៥១/៧០, សាលក្រម: អង្គសេចក្តី និងការបំពេញចិត្តដោយយុត្តិធម៌(កិច្ចប្រជុំពេញអង្គរបស់ ECHR), ២១ កុម្ភៈ ១៩៧៥ ត្រង់កថាខណ្ឌ៤៦។

[54] ករណី *Marckx ទល់នឹង ប្រទេសបែលស៊ិក,* សំណើសុំលេខ ៦៨៣៣/៧៤, សាលក្រម: អង្គសេចក្តី និងការបំពេញចិត្តដោយយុត្តិធម៌(កិច្ចប្រជុំពេញអង្គរបស់ ECHR), ១៣ មិថុនា ១៩៧៩ នៅ Holdings, កថាខណ្ឌ១៧។

[55] ករណី *Villagrán Morales និងគូកន ទល់នឹង Guatemala*, ស៊ីរី គ លេខ៧៧, សាលក្រម: សំណងទូទាត់ និងតម្លៃ (IACHR), ២៦ ឧសភា ២០០១ ត្រង់កថាខណ្ឌ៨៨។

"កាលៈទេសៈធ្ងន់ធ្ងរ" ជាពិសេសដែលនៅជិតខ្លួន[56] គឺតុលាការបានបំបែកឱ្យឃើញខុសគ្នារវាងករណី *Villagrán Morales* ពីករណីផ្សេងទៀតដែលថា សំណងទូទាត់ប្រកាសសិទ្ធិអាចជាការសមស្រប: *Villagrán Morales* ពាក់ព័ន្ធការធ្វើមនុស្សឃាតលើកុមារប្រាំនាក់។ ក្នុងករណី *Bronstein ទល់នឹង Peru,* តុលាការ IAtCHR បានធ្វើការកត់សម្គាល់ស្រដៀងគ្នានេះថា: "យោងតាមករណីយុត្តិសាស្ត្រអន្តរជាតិដ៏ទូលំទូលាយ តុលាការពិចារណាឃើញថាដើម្បីទទួលបានសាលក្រមមួយដែលការពារដល់ការទាមទាររបស់ជនរងគ្រោះ សាលក្រមនេះខ្លួនវាផ្ទាល់គឺជាទម្រង់មួយនៃការបំពេញចិត្ត"[57]។

២៨- ដោយសារតែវិសាលគមនៃករណីរឿងក្តីដែលទាំងតុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក (IACtHR) និងតុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប (ECtHR) បានបញ្ជាក់ថា សាលក្រមប្រកាសសិទ្ធិ គឺបង្កើតបានជាដំណោះស្រាយតាមផ្លូវច្បាប់គ្រប់គ្រាន់-សូម្បីតែនៅក្នុងករណីការរំលោភធ្ងន់ធ្ងរ ដូចជាការឃុំខ្លួនដោយខុសច្បាប់នោះក្តី - ក៏អង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តដោយភាន់ច្រឡំខាងអង្គច្បាប់ នៅក្នុងការសម្រេចជ្រើសយកឧបាស្រ័យនោះដែរ៖ គឺថានៅក្នុងការពោលអះអាងអំពីគោលការណ៍សន្មតជាមុនអំពីភាពមិនទាន់មានទោស, អំពីការព្រមានចំពោះបុគ្គលទាំងឡាយណាដែលនឹងរំលោភទៅលើគោលការណ៍សន្មតខាងលើនេះ និងការបញ្ជាក់ឡើងវិញជាដដែលៗអំពីឯករាជ្យភាពរបស់តុលាការ។ សហព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានថា ហេតុដូចនេះគឺមេធាវីការពារក្តីបានខកខានក្នុងការបំពេញ ទៅតាមសម្រាប់លក្ខខណ្ឌតម្រូវសម្រាប់ការចាប់ផ្តើមដំបូងនៃបទដ្ឋានស្តីពីការពិនិត្យឡើងវិញ លើកំហុសនានាខាងអង្គច្បាប់ ដែលធ្វើឱ្យខូចសុពលភាពសេចក្តីសម្រេចដែលកំពុងរងការជំទាស់នេះ។ គ្មានកំហុសខាងអង្គច្បាប់ណាមួយត្រូវបានបញ្ចេញឱ្យដឹងទេ ក្នុងអង្គជំនុំជម្រះសាលាដំបូងស្របទៅតាម "យុត្តិសាស្ត្រអន្តរជាតិដ៏ទូលំទូលាយ"[58] ដែលបានបង្កើតឡើងនូវភាពស្របច្បាប់នៃឧបាស្រ័យប្រកាសសិទ្ធិ។ ដូចគ្នានេះដែរ មេធាវីការពារក្តីខកខានមិនបានបង្ហាញឱ្យឃើញថា ការសម្រេចយករបស់អង្គ

---

[56] *ដដែលដូចខាងលើ*។

[57] ករណី *Bronstein ទល់នឹង Peru,* ស៊េរី គ លេខ៧៤, សាលក្រម: សំណងទូទាត់ និងតម្លៃ (IACHR), ៦ កុម្ភៈ ២០០១ ត្រង់កថាខណ្ឌ១៨៣។

[58] ដូចគ្នានឹងខាងលើត្រង់កន្លែងដែល។

ជំនុំជម្រះសាលាដំបូង នូវដំណោះស្រាយប្រកាសសិទ្ធិ និងការព្រមានជាសាធារណៈ ដើម្បីលើកឡើងដោះស្រាយចំពោះសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ដែលមិនគួរជាទីពេញចិត្តយ៉ាងខ្លាំងដែលថា ធ្វើឱ្យសេចក្តីសម្រេចអស់សុពលភាពទាំងស្រុងនោះឡើយ។

២៩- ទីពីរ ទាក់ទងអំពីកំហុសខាងអង្គច្បាប់ដែលបានចោទប្រកាន់ដោយមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនអាចទទួលយកបាននៃពាក្យសុំលើកទី១ សហព្រះរាជអាជ្ញាយល់ឃើញថាការពិនិត្យឡើងវិញមួយទៅលើកំណត់ហេតុទាក់ទងនឹងអង្គហេតុដែលបានចែងនៅក្នុងផ្នែកទីII(ក)ខាងលើ បានបង្ហាញសក្ខីកម្មយ៉ាងច្បាស់អំពីលក្ខណៈនៃដំណោះស្រាយបញ្ចប់នៃពាក្យសុំលើកទីមួយ ដែលបានធ្វើឡើងដោយផ្ទាល់មាត់ និងអំពីផលវិបាកនៃការមិនអាចទទួលយកបាននៃពាក្យសុំលើកទីមួយ។ បើសិនជាអង្គជំនុំជម្រះរកឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងអង្គច្បាប់នៅក្នុងរឿងនេះ សហព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានថា កំហុសណាមួយបែបនេះ គឺវាមិនធ្វើឱ្យសេចក្តីសម្រេចអស់សុពលភាពនោះឡើយ។ ដូចមេធាវីការពារក្តី "បានត្រៀមលក្ខណៈជាស្រេចក្នុងការទទួលស្គាល់ថា" កំហុសដែលបានចោទប្រកាន់ "គឺជាកំហុសដែលមិនធ្វើឱ្យមានការខូចខាត" នោះឡើយ[59]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចដូចគ្នាដដែលៗ ដោយគ្មានភ័ស្តុតាងបង្ហាញអំពីព្យសនកម្មនោះ ទោះបីជាកំហុសខាងអង្គច្បាប់ជាក់ស្តែង ក៏នឹងមិនត្រូវបានសម្រេចថា "អស់សុពលភាព" ដល់សេចក្តីសម្រេចដែលកំពុងរងការជំទាស់នោះដែរ[60]។ ដូចមានចែងនៅក្នុងផ្នែកទីII(ក)ខាងលើ លក្ខខណ្ឌតម្រូវក្នុងការធ្វើឱ្យអស់សុពលភាពនៅក្នុងយុត្តិសាស្ត្រនៃតុលាការ *ពិសេសនានា* គឺជាកញ្ចក់ឆ្លុះបញ្ចាំងអំពីបទដ្ឋាន

---

[59] ឯកសារលេខ **E176/2/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់លេខ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៩។

[60] *សូមអាន ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Galic,* សំណុំរឿងលេខ IT-98-29-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៦ ត្រង់កថាខណ្ឌទី២១ ។*ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Blaskic*, សំណុំរឿងលេខ IT-95-14-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី២៩ កក្កដា ២០០៤ ត្រង់កថាខណ្ឌទី២៩៩ ។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា នឹង Kordic*, សំណុំរឿងលេខ IT-95-14/2-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១៧ ធ្នូ ២០០៤ ត្រង់កថាខណ្ឌទី១៤៣ ។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា នឹងករណីរឿងក្តីរបស់រដ្ឋអាជ្ញា នឹង Haradinaj*, សំណុំរឿងលេខ IT-04-84-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី១៩ កក្កដា ២០១០ ត្រង់កថាខណ្ឌទី១៧ ។

នៅក្នុងវិធាន១០៥។ សហព្រះរាជអាជ្ញាលើកជាមតិថា ការតវ៉ាទាមទារណាមួយអំពីកំហុសដែលមិនធ្វើឲ្យមានការខូចខាតចាំបាច់ គឺត្រូវតែបរាជ័យ ដោយសារតែបំពេញមិនបានទៅតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

៣០- ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាជូនជាយោបល់ថា បណ្តឹងសាទុក្ខនេះត្រូវតែបរាជ័យ ដោយសារមិនបានបំពេញទៅតាមបទដ្ឋានជាធរមានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ សម្រាប់កំហុសនានាខាងអង្គច្បាប់។

*iii. អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិដែលអាចយល់បាន បណ្តាលឲ្យមានព្យសនកម្មដល់ដើមបណ្តឹងសាទុក្ខឡើយ*

៣១- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា នៅក្នុងសេចក្តីសម្រេចដែលរងការតវ៉ាមិនបានបង្ហាញឲ្យឃើញអំពី "កំហុសដែលអាចយល់បាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិដែលបណ្តាលឲ្យមានព្យសនកម្មដល់ដើមបណ្តឹងសាទុក្ខទេ"[61] ដូចដែលមេធាវីការពារក្តីបានចោទប្រកាន់ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ក្នុងការអនុញ្ញាតឲ្យចេញនូវដំណោះស្រាយប្រកាសសិទ្ធិ និងនូវការព្រមានជាសាធារណៈមួយ ជាជំនួសឲ្យការចេញការព្រមាន "ខ្លាំងៗ" ជាក់លាក់មួយចំពោះលោកនាយករដ្ឋមន្ត្រី[62] ព្រមទាំងឲ្យធ្វើការស៊ើបអង្កេតបន្ថែមទៀត[63]។

៣២- ដូចដែលបានលើកឡើងពិភាក្សារួចហើយនៅក្នុងផ្នែកទីII(ខ)(i)ខាងលើ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានធ្វើការរៀបរាប់អំពីបទដ្ឋានជាធរមាន សម្រាប់ពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងណាមួយ៖

---

[61] វិធាន១០៤(១)។

[62] ឯកសារលេខ **E176/2/1/1** បណ្តឹងសាទុក្ខ, កំណត់សម្គាល់លេខ១ *ខាងដើម* ត្រង់កថាខណ្ឌទី១៥-១៧។

[63] ឯកសារលេខ **E176/2/1/1** ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី១៨។

> *ដើមបណ្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញឱ្យឃើញថា សេចក្តីសម្រេច[របស់]អង្គជំនុំជម្រះសាលាដំបូង[...]មានភាពមិនសមហេតុសមផលយ៉ាងខ្លាំង ហើយថែមទាំងមិនមានភាពយុត្តិធម៌យ៉ាងជាក់ស្តែងទៀតផង ដែលធ្វើឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចទាញសេចក្តីសន្និដ្ឋានបានថា អង្គជំនុំជម្រះសាលាដំបូងប្រាកដជាខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយត្រឹមត្រូវនោះ*[64] ។

៣៣- ការធ្វើការប្រៀបធៀបអំពីយុត្តិសាស្ត្រដែលបានទាញយកមកពីតុលាការជាតិ និងអន្តរជាតិនានា បានជួយផ្តល់ឱ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិលើដំណោះស្រាយតាមផ្លូវច្បាប់នានាបានត្រឹមត្រូវ នៅចំពោះមុខនៃការជ្រៀតជ្រែកដ៏មានសក្តានុពលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ។ បន្ថែមពីលើឆន្ទានុសិទ្ធិទូទៅដែលតុលាការនានាតែងតែអនុវត្តក្នុងការសម្រេចចិត្តជ្រើសយកការផ្តល់នូវដំណោះស្រាយប្រកាសសិទ្ធិ ចំពោះការរំលោភសិទ្ធិមនុស្សនានាដូចដែលបានរៀបរាប់នៅក្នុងផ្នែកខាងដើម យុត្តិសាស្ត្រនានាដែលពាក់ព័ន្ធបានបង្ហាញថា សាលាដំបូងនានាត្រូវបានផ្តល់ឱ្យនូវភាពបត់បែន ជាពិសេសក្នុងការកំណត់អំពីថា តើត្រូវធ្វើយ៉ាងដូចម្តេចឱ្យបានប្រសើរបំផុតក្នុងការការពារឯករាជ្យភាពរបស់ខ្លួន។

៣៤- ក្នុងករណីរឿងក្តីរបស់ *Valente ទល់នឹង ព្រះមហាក្សត្រីយានី* តុលាការកំពូលនៃប្រទេសកាណាដា បានសង្កត់ធ្ងន់ថា ការខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់នូវការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ គឺមិនចាំបាច់តម្រូវឱ្យមាន "រូបមន្តដោយឡែកណាមួយខាងច្បាប់ ឬខាងរដ្ឋធម្មនុញ្ញ"ឡើយ[65]។ ផ្ទុយទៅវិញ *Valente* ប្រកាន់ជំហរយកសំណើថា ទោះជាបានចាត់វិធានការអ្វីមួយក៏ដោយ ដែលមានផលប្រយោជន៍បំផុតគឺថា "សារៈសំខាន់នៃសន្តិសុខដែលបានផ្តល់

[64] ករណីរឿងក្តីរបស់ *Tolimir,* កំណត់សម្គាល់លេខ៣៨ *ខាងដើម* [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។

[65] ករណីរឿងក្តីរបស់ *Valente ទល់នឹង ព្រះមហាក្សត្រីយានី, សំណុំរឿងលេខ* 17583,សាលដីកា (តុលាការកំពូលនៃប្រទេសកាណាដា), ចុះថ្ងៃទី១៩ ធ្នូ ១៩៨៥ ត្រង់កថាខណ្ឌទី២៥។

ឲ្យដោយលក្ខខណ្ឌជាសារវន្តស្ដីពីឯករាជ្យភាពរបស់តុលាការ” គឺត្រូវតែធានា[66]។

៣៥- តុលាការធម្មនុញ្ញនៃប្រទេសអាហ្វ្រិកខាងត្បូង ចាប់តាំងពីពេលនោះ បានអះអាងអំពីសេរីភាពក្នុងការសំដែងមតិដែលបានផ្ដល់ដោយសារការរកឃើញក្នុងករណីរឿងក្ដីរបស់ *Valente* ស្ដីពីឯករាជ្យភាពរបស់តុលាការ។ នៅក្នុងករណីរឿងក្ដីរបស់ *De Lange ទល់នឹង Smuth NO និងជនដទៃទៀត* តុលាការបានលើកមកសំអាងម្ដងហើយម្ដងទៀតទៅលើការវាយតម្លៃរបស់ *Valente អំពីឆន្ទានុសិទ្ធិ*របស់តុលាការ[67]ហើយនៅក្នុងករណីរឿងក្ដីរបស់ *S និងជនផ្សេងទៀត ទល់នឹង Van Rooyen និងជនដទៃទៀត* តុលាការបានសង្កត់ធ្ងន់ថា ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុងករណីរឿងក្ដីរបស់ *Valente* ស្ដីពីឯករាជ្យភាពរបស់តុលាការគឺជា“គោលគំនិតមួយដែលកំពុងតែវិវឌ្ឍន៍”[68]។ តុលាការពិសេស សម្រាប់ប្រទេសសៀរ៉ាឡេអូនបានរៀបរាប់ដោយលំអិតបន្ថែមទៀត ស្ដីពីកត្តាផ្សេងៗ ដែលអាចត្រូវយកចិត្តទុកដាក់នៅក្នុងពេលធ្វើការវាយតម្លៃទៅលើការរំលោភលើឯករាជ្យភាពរបស់តុលាការ *ដែលនៅក្នុងចំណោមកត្តាផ្សេងៗជាច្រើនទៀតអំពី* “សារៈសំខាន់នៃការជំនុំជម្រះក្ដីប្រកបដោយប្រសិទ្ធភាព និងដោយឆាប់រហ័សនៃតុលាការអន្តរជាតិ”[69]។ ហេតុដូចនេះ ការប្ដេជ្ញាចិត្តរបស់អង្គជំនុំជម្រះសាលាដំបូងដែលបញ្ជាក់ជាថ្មីឡើងវិញអំពីគោលការណ៍សច្ចធារណ៍និរទោស ដែលរំឭកឡើងវិញដល់មន្ត្រីនានា សុំឲ្យប្រកាន់ខ្ជាប់នូវគោលការណ៍នេះ និងដែលសង្កត់ធ្ងន់ទៅលើឯករាជ្យភាពរបស់អង្គជំនុំជម្រះផ្ទាល់ គួបផ្សំជាមួយនឹងភាពគ្រប់គ្រាន់ដើម្បីថែរក្សាការពារនូវ “សារៈសំខាន់នៃ

[66] *ដូចគ្នានឹងខាងលើត្រង់កន្លែងដែល។*

[67] ករណីរឿងក្ដីរបស់ *De Lange ទល់នឹង Smuts NO និងជនផ្សេងទៀត, សំណុំរឿងលេខ* CCT 26/97, សាលដីកា (តុលាការធម្មនុញ្ញនៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី២៨ ឧសភា ១៩៩៨ ត្រង់កថាខណ្ឌទី៧១-៧២។

[68] ករណីរឿងក្ដីរបស់ករណីរឿងក្ដីរបស់ *S និងអ្នកដទៃទៀត ទល់នឹង Van Rooyen និងជនដទៃទៀត, សំណុំរឿងលេខ* CCT 21/01, សាលដីកា(តុលាការធម្មនុញ្ញានៃប្រទេសអាហ្វ្រិកខាងត្បូង), ចុះថ្ងៃទី១១ មិថុនា ២០០២ ត្រង់កថាខណ្ឌទី៧៥។

[69] *ករណីរឿងក្ដីរបស់រដ្ឋអាជ្ញា ទល់នឹង Sam Hinga Norman,* សំណុំរឿងលេខ SCSL-04-14-PT-034-II, សេចក្ដីសម្រេចលើញត្តិបឋមដែលផ្អែកលើមូលដ្ឋានការគ្មានយុត្តាធិការ (ឯករាជ្យភាពរបស់តុលាការ) (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL: មតិផ្សេងពីគ្នារបស់លោកចៅក្រមប្រធានសាលាឧទ្ធរណ៍ Geoffrey Robertson), ចុះថ្ងៃទី១៣ មិនា ២០០៤ ត្រង់កថាខណ្ឌទី១៨។

សន្តិសុខដែលបានផ្តល់ឲ្យដោយលក្ខខណ្ឌជាសារវន្តនៃឯករាជ្យភាពរបស់តុលាការ" គឺជាការអនុវត្ត ឆន្ទានុសិទ្ធិដ៏ត្រឹមត្រូវមួយ ដែលត្រូវបានគាំទ្រយ៉ាងពេញទំហឹងដោយយុត្តិសាស្ត្រនៃតុលាការអន្តរជាតិ។ សេចក្តីសម្រេចដោយមានបញ្ជាក់មូលហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដោះស្រាយបណ្តឹង បន្ទាន់នេះ តាមរយៈដំណោះស្រាយប្រកាសសិទ្ធិ គឺជាជម្រើសមួយក្នុងចំណោមជម្រើសនានាដែលប ង្ហាញក្នុងវិធាន៣៥(២)[70] ដែលមកទល់ពេលនេះ ធ្វើឲ្យមានការខ្វះខាតដោយសារភាពមិនសមហេតុ សមផលយ៉ាងច្បាស់ និងអយុត្តិធម៌ជាក់ស្តែង ដែលតម្រូវឲ្យធ្វើការកែប្រែសាលក្រមឡើងវិញ ព្រោះ ដោយសារតែមូលហេតុរំលោភលើឆន្ទានុសិទ្ធិ។

៣៦- ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សាលក្រមដែលទាក់ទងនឹង ការអនុវត្តសិទ្ធិ និងការព្រមានជាសាធារណៈរបស់អង្គជំនុំជម្រះសាលាដំបូង មិនបំពេញទៅតាម បទដ្ឋានដែលថាសេចក្តីសម្រេចដែលកំពុងរងការតវ៉ានោះ "មានភាពមិនសមហេតុសមផលយ៉ាងច្បាស់ និងអយុត្តិធម៌យ៉ាងជាក់ស្តែងនោះឡើយ" ដែលតម្រូវឲ្យធ្វើការកែប្រែឡើងវិញ[71]។

## III. សេចក្តីសន្និដ្ឋាន

៣៧- អាស្រ័យដោយមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះមេត្តា៖

ក. ប្រកាសថាបណ្តឹងសាទុក្ខដែលសម្រេចបញ្ចប់លើសំណើសុំលើកទីមួយនេះ មិនអាច ទទួលយកបានទេ ព្រោះហួសពេលហើយ។

[70] វិធាន៣៥(២)។

[71] *ដូចគ្នានឹងខាងលើ។*

ខ. បដិសេធចោលបណ្តឹងសាទុក្ខនេះទាំងមូល ដោយសារតែខកខានមិនបានបំពេញទៅតាមបទដ្ឋានស្តីពីការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។

គ. កំណត់លើបណ្តឹងសាទុក្ខនេះ ដោយផ្អែកតែលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |